ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាធារណព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ០២
ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩
សាលដីកា
លេខ ២៤ "II"
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

## សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកស្រី [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៤៤០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាសំបូរ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣២ ក្រIV "ព.ន" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ដែលមាន ៖

- **ជនជាប់ចោទ** ៖ ឈ្មោះ [redacted] ស៊ីណាសំបូរ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរអ្នកយាមតារាងបាល់ទះ ទីកន្លែងកំណើតនៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន។ (ឃុំខ្លួនថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧)(អ្នកប្តឹងសាទុក្ខ)

-មានលោក [redacted] សុខុន ជាមេធាវីការពារ



Scanned with CamScanner

- **ជាប់ចោទពីបទ** រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១០F ផ្លូវលេខ ៦៥ ភូមិ១០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

- **ដើមបណ្តឹងរដ្ឋប្បវេណី ៖** ឈ្មោះ [redacted] កណ្ណ ភេទប្រុស អាយុ ៣២ឆ្នាំ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ៣៣ E៤ ផ្លូវលេខ ១៦៦ ក្រុមទី២ ភូមិ២ សង្កាត់អូរឫស្សី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

-**ជនរងគ្រោះ ៖** ឈ្មោះ [redacted] សុម៉ាលី ហៅ ស្រីអូន ភេទស្រី អាយុ ១៤ឆ្នាំ អាសយដ្ឋានបច្ចុប្បន្នផ្ទះ [redacted] រាជធានីភ្នំពេញ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ នៅចំណុចកើតហេតុខាងលើ មានករណីរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ មួយបានកើតឡើងដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ស៊ីណាសំបូរ ដោយមុនពេលកើតហេតុជនជាប់ចោទបានមានទំនាក់ទំនងជាមួយជនរងគ្រោះឈ្មោះ [redacted] សុម៉ាលី នៅផ្សារផេនសល ហើយជនជាប់ចោទបានចាប់ចិត្តស្រឡាញ់ និងលួងលោមរួមភេទជាមួយជនរងគ្រោះបានចំនួន ០៣លើក ដោយលើកទី០១ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ នៅផ្ទះរបស់ជនជាប់ចោទ លើកទី០២ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ និងលើកទី០៣ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ នៅផ្ទះសំណាក់ ។

សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៥៦៨ "ជ" ក្រ៦ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

ក.ផ្តន្ទាទោស

-ឈ្មោះ [redacted] ស៊ីណាសំបូរ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ។

ដាក់ពន្ធនាគារកំណត់ចំនួន ០៧ឆ្នាំ (ប្រាំពីរ) ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន។

ពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១០F ផ្លូវលេខ ៦៥ ភូមិ១០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ តាមបញ្ញតិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស។

ខ.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីណាសំបូរ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ សងសំណងជំងឺចិត្តចំនួន ១០.០០០$ (មួយម៉ឺនដុល្លារអាមេរិក) ទៅឲ្យដើមចោទបណ្តឹងរដ្ឋប្បវេណី។

-ការទាមទារលើសពីនេះបដិសេធចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។



Scanned with CamScanner

សាលក្រមនេះត្រូវបានឈ្មោះ [redacted] ស៊ីណាសំបូរ ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ ៧៧៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៣២ ក្រIV "រ.ន" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ ដែលមានខ្លឹមសារ នៃសេចក្ដីសម្រេចដូចតទៅ ៖

១.ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៧៧៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ របស់ជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណាសំបូរ ទុកជាត្រឹមត្រូវ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៦៨ (៥) គ្រ៦ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុច ក នៃសេចក្ដីសម្រេច គ្រង់ដាក់ពន្ធនាគារ កំណត់ចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ត្រូវតែប្រែមកជា "ដាក់ពន្ធនាគារកំណត់០៦ (ប្រាំមួយ) ឆ្នាំ វិញ ក្រៅពី ចំណុចនេះត្រូវរក្សាទុកជាបានការដដែល។

៣.បន្តការឃុំខ្លួនលើជនជាប់ចោទតាមច្បាប់។

៤.សាលដីកានេះ ត្រូវបានជំនុំជម្រះនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធឲ្យជនជាប់ចោទ ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។

សាលដីកានេះត្រូវបានឈ្មោះ [redacted] ស៊ីណាសំបូរ ប្ដឹងសាទុក្ខតាមបណ្ដឹងលេខ ៤៤០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានថា តាមការពិនិត្យទៅលើរឿង ហេតុ ឃើញថា ការសម្រេចរបស់សាលាឧទ្ធរណ៍ដែលតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការ ដដែល ដោយគ្រាន់តែកែប្រែចំណុច ទណ្ឌកម្មពី ០៧ឆ្នាំ មក ០៦ឆ្នាំវិញនោះគឺមានសំអាងហេតុត្រឹមត្រូវ តាមច្បាប់ ព្រោះថា ជនជាប់ចោទបានសារភាពថាខ្លួនធ្លាប់បានរួមភេទជាមួយជនរងគ្រោះចំនួន ០៣លើក និងគ្រាន់តែសុំបន្ធូបន្ថយទោសឱ្យខ្លួនតែប៉ុណ្ណោះ។ ម្យ៉ាងទៀង បើពិនិត្យលើជនរងគ្រោះឃើញថា ជាអនីតិ ជនអាយុ ១៤ឆ្នាំជា ដូចមាននៅក្នុងសំអាងហេតុចំណុចទី២ និងទី៤ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់។ ដូច្នេះតំណាងមហាអយ្យការសុំតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣២កIV "រ.ន" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០១៨ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

Scanned with CamScanner

- ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាស់បូរ បានឆ្លើយថា ខ្លួនមិនបានប្តឹងមកតុលាការកំពូល ដោយសារតែទោសច្រើនពេក និងចង់សុំឱ្យតុលាការជួយបន្ធូបន្ថយទោសឱ្យខ្លួន ដើម្បីឆាប់បានចេញទៅមើលថែឪពុក ម្តាយនៅខាងក្រៅ។ ខ្លួនសុំឱ្យតុលាការបន្ថយទោសមកត្រឹម ០២ឆ្នាំ។

- លោកមេធាវី [redacted] សុខុន បានធ្វើសេចក្តីសន្និដ្ឋានការពារជនជាប់ចោទថា សាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ០៧ឆ្នាំ និងសាលាឧទ្ធរណ៍សម្រេចដាក់ទោសអប្បបរិមាសម្រាលនៅត្រឹម ០៦ឆ្នាំ។ ក៏ប៉ុន្តែបើយោងមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ កាលៈទេសៈនៃបទល្មើសដោយសារកូនក្តីខ្លួនបានសារភាពនៅគ្រប់ដំណាក់កាលទាំងសាលាដំបូង និងសាលាឧទ្ធរណ៍ រួចហើយថាកូនក្តីខ្លួន និង [redacted] សុម៉ាលី បានស្រឡាញ់គ្នាទៅវិញទៅមក ហើយការរួមភេទនោះ គឺធ្វើឡើងដោយការស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំអ្វីនោះទេ។ មួយវិញទៀតដោយសារតែលោកស្រី [redacted] សុម៉ាលី ចង់បានកូនក្តីរបស់ខ្លួនជាគូអនាគត ក៏ប៉ុន្តែកូនក្តីខ្លួន បានមានប្រពន្ធកូន រួចហើយ ឃើញបែបនេះ បងរបស់នាងក៏បានដាក់ពាក្យបណ្តឹងមកលើលើកូនក្តីខ្លួនតែម្តង។ យោងតាមអង្គហេតុ និង អង្គច្បាប់ខ្លួនសំណូមពរសុំឱ្យប្រធានក្រុមប្រឹក្សា មេត្តាពិចារណាឱ្យកូនក្តីខ្លួនទទួលបានស្ថានសម្រាលអប្បបរិមាមកត្រឹម ០២ ឆ្នាំ។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៤០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលជនជាប់ចោទ ក៏ដូចជាមេធាវីរបស់ជនជាប់ចោទដែរលើកឡើងថា [redacted] ស៊ីណាស់បូរ និង [redacted] សុម៉ាលី បានស្រឡាញ់គ្នាទៅវិញទៅមក ហើយការរួមភេទនេះ គឺដោយមានការស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ។ ដូច្នេះសុំឱ្យតុលាការកំពូលបន្ធូបន្ថយទោសមកត្រឹម ២ឆ្នាំ នោះតុលាការកំពូលពិនិត្យឃើញថា ទោះបីជាមានការស្ម័គ្រចិត្តក្តី ក៏ប៉ុន្តែជនរងគ្រោះទើបមានអាយុជាង ១៤ឆ្នាំ ដែលច្បាប់មិនទាន់ទទួលស្គាល់ការព្រមព្រៀងរួមភេទនៅឡើយ។ ឯការដែលសុំឱ្យបន្ធូរទោសនោះ តុលាការកំពូលមិនអាចទទួលពិចារណាបានទេ ព្រោះតុលាការកំពូលពេលនេះជម្រះតែលើអង្គច្បាប់ ហើយសាលាឧទ្ធរណ៍បានផ្តល់ទោសកម្រិតទាបហើយ។

៣-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ មិនមានមូលហេតុដូចការកំណត់នៃមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។



Scanned with CamScanner

៤-យល់ឃើញថា សាលដីកាលេខ ៣២ ក្រIV "វ.ន" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ ត្រឹមត្រូវនឹងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- បដិសេធបណ្តឹងសាទុក្ខលេខ ៤៤០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣២ ក្រIV "វ.ន" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ទាំងមូល។

*សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសនៅការជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។*

Scanned with CamScanner